**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

-សំណុំរឿងព្រហ្មទណ្ឌលេខៈ ៥៦១
ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១
-សាលក្រមព្រហ្មទណ្ឌលេខៈ ៥១ "ជ"
ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តតាកែវ នាថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០២២ វេលាម៉ោង ២ និង ៣០នាទីរសៀល ដោយមានសមាសភាពចូលរួមដូចតទៅៈ

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តតាកែវ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តតាកែវ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៥៦១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ ដែលមានជនជាប់ចោទៈ

-ឈ្មោះ [redacted] សៀងលី ភេទស្រី អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តតាកែវ។ (គេចខ្លួន)

ជាប់ចោទពីបទៈ ផ្តល់សេចក្តីប្រកាសដោយភូតកុហក, បំភាន់មន្ត្រីសុរិយោដីក្នុងការចុះបញ្ជីដី និងបទៈ លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅចំណុចភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦៣៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៥២ និងមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

-ដោយមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សៀងលី។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ុនហេង កាន់អត្តសញ្ញាណប័ណ្ណលេខៈ [redacted] (០១) សញ្ជាតិខ្មែរ មានទីលំនៅផ្ទះលេខ B3 ផ្លូវ12BT ភូមិសន្សំកុសល៤ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។



Scanned with CamScanner

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនវណ្ណ កាន់អត្តសញ្ញាណប័ណ្ណលេខៈ [redacted] សញ្ជាតិខ្មែរ មានទីលំនៅផ្ទះលេខៈ ៣A ផ្លូវ ៣២០ ក្រុម២៩ សង្កាត់បឹងកេងកង ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

-ដោយមានលោក [redacted] មានអត្តលេខៈ [redacted] ជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនហេង និងឈ្មោះ [redacted] ប៊ុនវណ្ណ។

-បានឃើញ ពាក្យបណ្ដឹងចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ប៊ុនហេង និងឈ្មោះ [redacted] ប៊ុនសុវណ្ណ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ០៧៤ ដ.ស.ព/២២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ៩៤ /២២ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ១៦៣ ដចត/២២ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តតាកែវ។

-បានឃើញឯកសារផ្សេងៗក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។

**អង្គហេតុដែលប្ដឹងមកតុលាការមានដូចតទៅៈ**

កាលពីថ្ងៃមិនចាំ ខែកញ្ញា ឆ្នាំ២០០៨ ឈ្មោះ [redacted] ប៊ុនថុង ភេទប្រុស អាយុ៦៤ឆ្នាំ, ឈ្មោះ [redacted] ប៊ុន ហេង ភេទប្រុស អាយុ៥១ឆ្នាំ បានរួមគ្នាទិញដីមួយកន្លែងដែលមានទំហំ ១៦៧,៦៣៤ (មួយរយហុកសិបប្រាំពីរក្បៀសប្រាំមួយរយសាមសិបបួន) ម៉ែត្រការ៉េ ដែលមានទីតាំងមួយស្ថិតនៅភូមិថ្មី សង្កាត់កណ្ដោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់អចលវត្ថុលេខៈ ០៥០២០២០១-១៣៧៥ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ។ លុះដល់ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៩ ឈ្មោះ [redacted] ប៊ុនថុង បានទទួលមរណៈភាព ហើយនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ និងនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] សៀងលី ភេទស្រី អាយុ៣៦ឆ្នាំ រស់នៅភូមិប្រហ៊ូត សង្កាត់រការក្រៅ ក្រុងដូនកែវ ខេត្តតាកែវ ត្រូវជាមិត្តស្រីរបស់ឈ្មោះ [redacted] ប៊ុនថុង បានភូតកុហកតុលាការថា ដីខាងលើជាដីមរតករបស់ឈ្មោះ [redacted] ប៊ុនថុង ហើយនៅខែមិនចាំ ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] សៀងលី ក៏បានទៅបំភាន់មន្ត្រីសុរិយោដីដើម្បីចុះបញ្ជីដីធ្លី ដោយបានដាក់ឈ្មោះខ្លួនធ្វើជាម្ចាស់កម្មសិទ្ធិតែម្នាក់ឯង និងបានលក់ដីនោះទៅឱ្យឈ្មោះ [redacted] ហៃ ភេទប្រុសអាយុ៥៣ឆ្នាំ រស់នៅភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**នាពេលសវនាការ**

-អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនសុវណ្ណ បានឆ្លើយថាៈ ខ្ញុំបាទ និងឈ្មោះ [redacted] ប៊ុនហេង ត្រូវជាប្អូនបង្កើតរបស់ខ្ញុំបាទ រួមជាមួយឈ្មោះ [redacted] ប៊ុនថុង ត្រូវជាពូបង្កើតរបស់ខ្ញុំបាទ បានរួមគ្នាទិញដីចំនួនមួយកន្លែងដែលមានទំហំ ១៦៧,៦៣៤ (មួយរយហុកសិបប្រាំពីរក្បៀសប្រាំមួយរយសាមសិបបួន)



Scanned with CamScanner

ម៉ែត្រការ៉េ ដែលមានទីតាំងមួយស្ថិតនៅភូមិថ្មី សង្កាត់កណ្ដោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានចំណែកខ្ញុំបាទចំនួន ១០% ឈ្មោះ [redacted] ប៊ុនហេង ចំនួន២៥% និងឈ្មោះ [redacted] ប៊ុនថុង ចំនួន ៦៥% ហើយខ្ញុំបាទ និងឈ្មោះ [redacted] ប៊ុនថុង ឈរឈ្មោះ ជាកម្មសិទ្ធិប្លង់ដីនោះ។ បន្ទាប់មកឈ្មោះ [redacted] ប៊ុនថុង គាត់បានស្លាប់នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៩ ហើយស្រាប់តែនៅអំឡុងឆ្នាំ២០២០ ឈ្មោះ [redacted] សៀងលី បានភូតកុហកតុលាការ ដីដែលមានទំហំដូចខាងលើនេះ គឺជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ប៊ុនថុង តែម្នាក់ឯង ហើយឈ្មោះ [redacted] សៀងលី ក៏បានទៅបំភាន់មន្ត្រីសុរិយោដីក្នុងការចុះបញ្ជីដីធ្លី ដោយបានដាក់ឈ្មោះខ្លួនធ្វើជាម្ចាស់កម្មសិទ្ធិតែម្នាក់ឯងរួមហើយព្រមទាំងបានលក់ដីនោះទៅឈ្មោះ [redacted] ហៃ ភេទប្រុស មានទីលំនៅបច្ចុប្បន្នផ្ទះលេខ B៥៣ ផ្លូវលេខ ២ TB ភូមិទួលគោក សង្កាត់រកាក្រៅ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ និងឈ្មោះ [redacted] ថេងស្រ៊ាង មានទីលំនៅផ្ទះលេខ ២៧០ E0 ផ្លូវលេខ៩០ ភូមិ១១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ នៅក្នុងរឿងនេះខ្ញុំបាទសុំប្ដឹងទាមទារសំណងការខូចខាតចំនួន ២,០០០,០០០ (ពីរលាន) ដុល្លារអាមេរិក និងសំណងជំងឺចិត្តចំនួន ២៥០,០០០ (ពីរសែនប្រាំម៉ឺន) ដុល្លារអាមេរិក។

-លោក [redacted] ជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនហេង និងឈ្មោះ [redacted] ប៊ុនសុវណ្ណ បានធ្វើសេចក្ដីសន្និដ្ឋានថា: ខ្ញុំបាទសូមរក្សានូវការទាមទារដូចមានក្នុងពាក្យបណ្ដឹងចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ របស់កូនក្ដីខ្ញុំបាទទុកដដែល។

-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា: ក្រោយពីបានបញ្ចប់កិច្ចពិភាក្សាដេញដោលនេះ តំណាងអយ្យការសុំឱ្យតុលាការពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់។

-តាមសេចក្ដីសន្និដ្ឋានការពារចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សៀងលី បានសន្និដ្ឋានថា: នាងខ្ញុំសូមបដិសេធការចោទប្រកាន់តាមពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] អ៊ីលដា ចោលទាំងស្រុង និងសូមធ្វើការបកស្រាយអំពីអង្គហេតុដូចតទៅ: កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ សាលាដំបូងខេត្តកំពង់ស្ពឺបានចេញដីកាសម្រេចលេខ: ៦៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ដែលបានសម្រេច: ១. ទទួលស្គាល់កូនក្ដីនាងខ្ញុំឈ្មោះ [redacted] សៀងលី ភេទស្រី កើតថ្ងៃទី០២.០៨.១៩៨៤ ជនជាតិខ្មែរ ការន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ១០១០៥០៦៣៦ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២៩១៥ ជាសហព័ទ្ធរបស់មតកជន (ជា ប៊ុនថុង) ត្រូវក្លាយជាសន្តតិជនជានិច្ច។ ២.ប្រគល់ដី និងផ្ទះជាមត៌កពីសពឈ្មោះ [redacted] ប៊ុនថុង ដែលមាន: ក.ផ្ទះនិងដីទំហំ ១៦១ ម$^2$ ក្បាលដីលេខ ៧២៣ ស្ថិតនៅភូមិពាណិជ្ជកម្ម សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០៣០២-០៧២៣ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦, ខ.ដីមានទំហំ ១៩៨៨៦ ម$^2$ លេខក្បាលដី ១៤០៩ ស្ថិតនៅភូមិថ្មី សង្កាត់កណ្ដោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០២០១-១៤០៩ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨, គ.ដីមានទំហំ ៦៥០១ ម$^2$ លេខក្បាលដី ១៤០៨ ស្ថិតនៅភូមិថ្មី សង្កាត់កណ្ដោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០២០១-១៤០៨ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨, ឃ.ដីមានទំហំ ៦២៧៤ ម$^2$ លេខក្បាលដី ១៤០៧ ស្ថិតនៅភូមិថ្មី សង្កាត់កណ្ដោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០២០១-១៤០៧ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨, ង.ដីមានទំហំ ២៨៨១ ម$^2$



Scanned with CamScanner

លេខក្បាលដី ១៣១២ ស្ថិតនៅភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៥០២០២០១-១៣១២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨, ច.ដីមានទំហំ ៤៤៦៥ ម² លេខក្បាលដី ១៤០៦ ស្ថិតនៅភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៥០២០២០១-១៤០៦ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨, ឆ.ដីមានទំហំ ៦៣៨៦ ម² លេខក្បាលដី ១៤០៥ ស្ថិតនៅភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៥០២០២០១-១៤០៥ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨, ជ.ដីមានទំហំ ១៦៧៦៤៣ ម² លេខក្បាលដី ១៣៧៥ ស្ថិតនៅភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៥០២០២០១-១៣៧៥ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២, ឈ.ដីមានទំហំ ៥៨២២៩ ម² លេខក្បាលដី ១៣៧៦ ស្ថិតនៅភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៥០២០២០១-១៣៧៦ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២, ញ.ដីមានទំហំ ៥៣៣៤០ ម² លេខក្បាលដី ១៣៧៧ ស្ថិតនៅភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៥០២០២០១-១៣៧៧ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២, ដ.ដីមានទំហំ ៩៤៤៩ ម² លេខក្បាលដី ១៣៩៩ ស្ថិតនៅភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៥០២០២០១១៣-៩៩ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២, ឋ.ដីមានទំហំ ១១៧៩៨៥ ម² លេខក្បាលដី ១៣៩៦ ស្ថិតនៅភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៥០២០២០១-១៣៩៦ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២, ឌ.ដីមានទំហំ ៤៤២៥៣ ម² លេខក្បាលដី ១៨០ ស្ថិតនៅភូមិកោះគ្របបាយ សង្កាត់សំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០៨១៤១២-០១៨០ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២, ឍ.ផ្ទះលេខB១២ ទំហំ ៦៤ម² ស្ថិតនៅភូមិព្រៃព្រីងត្បូង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ មានព្រំប្រទល់ខាងជើងទល់នឹងB១១ ខាងកើតទល់នឹងផ្លូវ៨ម៉ែត្រ ខាងត្បូងទល់នឹង B១៣ ខាងលិចទល់នឹងផ្លូវ១២ម៉ែត្រ ដោយមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដី/ផ្ទះលេខៈ ៤៦៧៩ ប.ជ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ឱ្យមកឈ្មោះ [redacted] សៀងលី ភេទស្រី កើតថ្ងៃទី០២.០៨.១៩៨៤ ជនជាតិខ្មែរ ការន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ ១០១០៥០៦៣៦ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២៩១៥។ និងកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ សាលាដំបូងខេត្តកំពង់ស្ពឺបានចេញដីកាសម្រេចលេខ ៥៣៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ ដែលបានសម្រេចៈ ១.ប្រគល់ដី និងផ្ទះជាមត៌កពីសព ឈ្មោះ [redacted] ប៊ុនថុង ដែលមាន៖ ក.ដីមានទំហំ ៥០០ ម² លេខក្បាលដី ១៣១ ស្ថិតនៅភូមិបុរីកម្មករ សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០២០៣០៣-០១៣១ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤, ខ.ដីមានទំហំ ៣៣២៩ ម² លេខក្បាលដី ១៤០៤ ស្ថិតនៅភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៥០២០២០១-១៤០៤ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨, គ.ផ្ទះល្វែង ឡូតិ៍លេខD២៩ ដែលមានទំហំ ៤ម x ១៦ម ស្ថិតនៅក្រុមទី៣ ភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងជើងទល់នឹងប្រកផ្លូវ ខាងកើតទល់នឹងផ្ទះលេខD២៧ ខាងត្បូងទល់នឹងផ្លូវ ខាងលិចទល់នឹងផ្ទះលេខD៣១ មានលិខិតផ្ទេរ

សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ០៦០ កច្រ១ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ឱ្យមកឈ្មោះ [redacted] សៀងលី កើតថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៨៤ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ ១០១០៥០៦៣៦ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ដែលត្រូវជាសហព័ទ្ធរបស់មតកជនឈ្មោះ [redacted] ប៊ុនថុង។ ហើយបន្ទាប់មកទៀតនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០ កូនក្តីនាងខ្ញុំបានលក់អចលនវត្ថុមួយទីតាំងទៅឱ្យឈ្មោះ [redacted] ថេងស្រ៊ាង ដែលមានទំហំ ១៦១ម² លេខក្បាលដី ៧២៣ មានទីតាំងស្ថិតនៅភូមិពាណិជ្ជកម្ម សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០២០៣០២-០៧២៣ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ ក្នុងតម្លៃសរុប USD ១១៥,០០០ (ដប់មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក)។ ការទិញលក់តាមរយៈកិច្ចសន្យានេះត្រូវបានអនុវត្តចប់សព្វគ្រប់ដោយ [redacted] ថេងស្រ៊ាង បានប្រគល់ប្រាក់គ្រប់ចំនួន ហើយកូនក្តីនាងខ្ញុំ ([redacted] សៀងលី) បានផ្ទេរកម្មសិទ្ធិលើអចលនវត្ថុជូន [redacted] ថេងស្រ៊ាង តាមនីតិវិធីសុរិយោដីចប់សព្វគ្រប់។ គួរបញ្ជាក់ផងដែរថាកូនក្តីនាងខ្ញុំ (ឆាយ សៀងលី) ពិតជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុប្រាកដមែនតាមរយៈដីកាសម្រេចលេខៈ ៦៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ស្ពឺ។ ក្រោយមកទៀតកូនក្តីនាងខ្ញុំ (ឆាយ សៀងលី) បានលក់ដីបន្ថែមដែលគាត់ទទួលបានតាមរយៈដីកាសម្រេចលេខៈ ៥៣៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ ឱ្យទៅ [redacted] ថេងស្រ៊ាង និងលោក [redacted] ហៃ ដោយពួកគាត់បានទិញចូលហ៊ុនគ្នាទិញនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១។ ដោយ [redacted] ថេងស្រ៊ាង បានចូលហ៊ុនចំនួន ២៥% និងលោក [redacted] ហៃ ចូលហ៊ុនចំនួន ៧៥% ដែលមានទំហំសរុប ៤៥៣០៣៩ ម៉ែត្រការ៉េតម្លៃសរុប ៩០៦,០៧៨$ បានប្រគល់ប្រាក់លើកទី០១ចំនួន ៤០០,០០០$ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០ និងប្រគល់ប្រាក់បង្គ្រប់ ១០០% ចំនួន ៥០៦,០៧៨$ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០។ កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ ជី ហៃ បានទិញអចលនវត្ថុ ០២ ទីតាំង ដែលក្នុងនោះមានអចលនវត្ថុទី០១ មានទំហំ ៥០០ ម² មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០២០៣០៣-០១៣១ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ មានទីតាំងស្ថិតនៅភូមិបុរីកម្មករ ឃុំរកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ក្នុងតម្លៃទិញលក់ ១០៥,០០០$ ដុល្លារអាមេរិក និងអចលនវត្ថុទី២ មានទំហំ ៣៣២៩ ម² មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០២០២០១-១៤០៤ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ក្នុងតម្លៃ ៣ដុល្លារ ក្នុងមួយម៉ែត្រការ៉េ នាំឱ្យតម្លៃសរុបស្មើនឹង ៩៩៨៧ ដុល្លារអាមេរិក ដូចមានយោងក្នុងកិច្ចសន្យាទិញលក់ដី និងផ្ទះ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១។ ការទិញលក់គឺបានអនុវត្តតាមកិច្ចសន្យាចប់សព្វគ្រប់ ដោយ [redacted] ថេងស្រ៊ាង និង [redacted] ហៃ បានប្រគល់ប្រាក់គ្រប់ចំនួន ហើយកូនក្តីនាងខ្ញុំបានផ្ទេរកម្មសិទ្ធិជូនពួកគាត់រួចរាល់តាមលក្ខខណ្ឌនៃកិច្ចសន្យា។ ក្រោយទិញដីនេះរួច ពេល [redacted] ថេងស្រ៊ាង និង [redacted] ហៃ ចូលកាន់កាប់ទើបឃើញមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយកំពុងសាងសង់ និងដឹងថាឈ្មោះ [redacted] អ៊ីលដា បានជួលដីនេះទាំងខ្លួនពុំមានសិទ្ធិកម្មសិទ្ធិ ហើយបានពឹងពាក់មេធាវីមកប្តឹងតាមផ្លូវតុលាការតាមនីតិវិធីច្បាប់រហូតមកទល់បច្ចុប្បន្ន។ ចំពោះការប្តឹងព្រហ្មទណ្ឌគឺបុគ្គលនេះធ្លាប់បានប្តឹងកូនក្តីនាងខ្ញុំនៅសាលាដំបូងខេត្តកំពង់ស្ពឺរួចហើយ ហើយ *ត្រូវបានអយ្យការអមសាលាដំបូងតម្កល់រឿងទុកឥតចាត់ការ* និង *ត្រូវបានមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញសម្រេចតម្កល់សេចក្តីសម្រេចរបស់សាលាដំបូង* ។ អាស្រ័យហេតុនេះការចោទប្រកាន់របស់ ជា

អ៊ីលដា ជាការមួលបង្កាច់បង្ខូចកេរ្តិ៍កូនក្តីនាងខ្ញុំទាំងស្រុង ហើយនាងខ្ញុំស្នើសុំ ឯកឧត្តមប្រធាន មេត្តាសម្រេចឱ្យកូនក្តីនាងខ្ញុំរួចទោស។

-ក្រោយពីបាន ស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបាន ពិនិត្យឯកសារ និងភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង ។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹង។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ក្រោយពីបាន ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១-ក្រោយពីធ្វើការស៊ើបសួរតាមនីតិវិធីចប់សព្វគ្រប់ហើយចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយលេខៈ ៩៤/២២ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ដោយបានសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] សៀងលី ភេទស្រី អាយុ៣៦ឆ្នាំ មកជំនុំជម្រះពីបទៈ ផ្តល់សេចក្តីប្រកាសដោយភូតកុហក, បំភាន់មន្ត្រីសុរិយោដីក្នុងការចុះបញ្ជីដី និងបទៈ លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅចំណុចភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦៣៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៥២ និងមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

២-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងឯកសារផ្សេងៗដែលមានក្នុងសំណុំរឿង បញ្ជាក់ឱ្យឃើញថាៈ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០០៨ ជនរងគ្រោះឈ្មោះ [redacted] ប៊ុនហេង និងឈ្មោះ [redacted] ប៊ុនសុវណ្ណ បានចូលលុយគ្នាជាមួយនឹងពូរបស់គេឈ្មោះ [redacted] ប៊ុនថុង ដើម្បីទិញដីមួយកន្លែងដែលមានទំហំ ១៦៧,៦៣៤ (មួយរយហុកសិបប្រាំពីរក្បៀសប្រាំមួយរយសាមសិបបួន) ម៉ែត្រការ៉េ មានទីតាំងមួយស្ថិតនៅភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់អចលវត្ថុលេខៈ ០៥០២០២០១-១៣៧៥ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២ ចេញដោយមន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយដីខេត្តកំពង់ស្ពឺ។ ក្រោយពេលទិញដីខាងលើរួចហើយ គឺប្លង់ដីដែលជនរងគ្រោះឈ្មោះ [redacted] ប៊ុនហេង និងឈ្មោះ [redacted] ប៊ុនសុវណ្ណ ដែលបានចូលលុយទិញជាមួយនឹងពូរបស់គេឈ្មោះ [redacted] ប៊ុនថុង កន្លងមកនោះ គឺបានរក្សាទុកនៅនឹងឈ្មោះ ជា ប៊ុនថុង រហូតមក។ ស្រាប់តែនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៩ ឈ្មោះ [redacted] ប៊ុនថុង បានទទួលមរណៈភាព ហើយប្លង់ដីនោះក៏ត្រូវបានជនជាប់ចោទឈ្មោះ [redacted] សៀងលី ដែលត្រូវជាមិត្តស្រីរបស់ឈ្មោះ [redacted] ប៊ុនថុង បានអ្នកកកាន់កាប់ទុកតែម្តងទៅ។ ក្រោយមកនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ និងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] សៀងលី ក៏បានប្តឹងមកតុលាការថាៈ អចលនវត្ថុខាងលើនេះ គឺជាដីមត៌ករបស់ឈ្មោះ [redacted] ប៊ុនថុង តែម្នាក់ឯង ដោយមិនមានសហម្ចាស់កម្មសិទ្ធិមួយណាបានទិញរួមគ្នានោះទេ ហើយតុលាការក៏បានសម្រេចទទួលស្គាល់តាមការអះអាងរបស់ឈ្មោះ [redacted] សៀងលី ហើយឈ្មោះ [redacted] សៀងលី ក៏បានបន្តយកសេចក្តីសម្រេចនោះទៅប្រកាស និងបំភាន់ដល់មន្ត្រីសុរិយោដីខេត្តកំពង់ស្ពឺថាដីខាងលើនេះជាដីមត៌ករបស់ឈ្មោះ [redacted] ប៊ុនថុង ដែលបានទទួលមរណភាពដោយមិនមានអ្នកដែលត្រូវទទួល

មត៌កបន្តក្រៅពីខ្លួនដែលជាសហព័ទ្ធតែម្នាក់នោះទេ រួចហើយខាងមន្ត្រីសុរិយោដីក៏បានធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុខាងលើនេះឱ្យទៅគេ (ឈ្មោះ [redacted] សៀងលី) ហើយឈ្មោះ [redacted] សៀងលី ក៏បានបន្តយកអចលនវត្ថុខាងលើនេះ ទាំងដែលពុំមែនជាកម្មសិទ្ធិរបស់ខ្លួនទៅលក់ឱ្យឈ្មោះ [redacted] ហៃ និងឈ្មោះ [redacted] ថេងស្រ៊ាង បាត់អស់តែម្តង។ ក្រោយមកជនរងគ្រោះឈ្មោះ [redacted] ប៊ុនហេង និងឈ្មោះ [redacted] ប៊ុនសុវណ្ណ ដែលត្រូវជាក្មួយរបស់មត៌កជនឈ្មោះ [redacted] ប៊ុនថុង ក៏បានដាក់ពាក្យបណ្តឹងចូលមកអយ្យការអមសាលាដំបូងខេត្តតាកែវដើម្បីចាត់ការតាមផ្លូវច្បាប់។

៣-យល់ឃើញថា: អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សៀងលី ដែលបានភូតកុហកដល់មន្ត្រីសាធារណ:ថាអចលនវត្ថុដែលមានវិញ្ញាបនបត្រសម្គាល់អចលវត្ថុលេខ: ០៥០២០២០១-១៣៧៥ ថាជាមត៌ករបស់មតកជនឈ្មោះ [redacted] ប៊ុនថុង តែម្នាក់គត់ និងមិនមានសន្តតិជនផ្សេងក្រៅពីខ្លួនដែលជាអ្នកត្រូវទទួល ព្រមទាំងបានបំភាន់ដល់មន្ត្រីសុរិយោដីឱ្យចុះបញ្ជីផ្ទេរមកឱ្យខ្លួនជាម្ចាស់កម្មសិទ្ធិ ហើយក៏បានយកអចលនវត្ថុខាងលើនោះទៅលក់ឱ្យអ្នកដទៃ ដោយចេតនាទុច្ចរិតគឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណ: និងសន្តិសុខសង្គម ជាពិសេសធ្វើឱ្យបាត់បង់ និងខូចប្រយោជន៍ស្របច្បាប់របស់អ្នកដទៃទៀតផង ហើយអំពើនេះទៀតសោតត្រូវបានច្បាប់ហាមឃាត់ និងកំណត់ថាជាបទ: ផ្តល់សេចក្តីប្រកាសដោយភូតកុហក, បំភាន់មន្ត្រីសុរិយោដីក្នុងការចុះបញ្ជីដី និងបទ: លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦៣៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៥២ និងមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

៤-យល់ឃើញថា: ជនជាប់ចោទឈ្មោះ [redacted] សៀងលី ភេទស្រី អាយុ៣៦ឆ្នាំ គឺជានីតិជនមានស្មារតីយល់ដឹង គ្រប់គ្រាន់នូវលទ្ធផលដែលកើតចេញពីអំពើរបស់ខ្លួន និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលកើតចេញពីអំពើរបស់ខ្លួន។

៥-យល់ឃើញថា: មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] សៀងលី ភេទស្រី អាយុ៣៦ឆ្នាំ ពីបទ: ផ្តល់សេចក្តីប្រកាសដោយភូតកុហក, បំភាន់មន្ត្រីសុរិយោដីក្នុងការចុះបញ្ជីដី និងបទ: លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅចំណុចភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ ២០២០ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦៣៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៥២ និងមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

៦-តាមសេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនហេង និងឈ្មោះ [redacted] ប៊ុនសុវណ្ណ ដោយសុំឱ្យតុលាការសម្រេចអំពីសំណងតាមការទាមទាររបស់កូនក្តីខ្លួន និងសម្រេចអំពីសំណងជំងឺចិត្តផងដែរ។ តុលាការយល់ឃើញថា: ការស្នើសុំនេះមានមូលដ្ឋានតាមផ្លូវច្បាប់ និងមានមូលហេតុសមរម្យ គប្បីតុលាការទទួលយកមកពិចារណា។

៧-តាមការប្តឹងសុំរបស់តំណាងអយ្យការដោយសុំឱ្យតុលាការពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់លើជនជាប់ចោទឈ្មោះ [redacted] សៀងលី។ ហេតុនេះគប្បីតុលាការសម្រេចពិចារណា។



Scanned with CamScanner

៨-តាមសេចក្តីសន្និដ្ឋានការពារចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទថា: ចំពោះការប្តឹងព្រហ្មទណ្ឌ គឺបុគ្គលនេះធ្លាប់បានប្តឹងកូនក្តីខ្លួន (ជា អ៊ីលជា) នៅសាលាដំបូងខេត្តកំពង់ស្ពឺរួចហើយ ហើយត្រូវបានអយ្យការអមសាលាដំបូងតម្កល់រឿងទុកឥតចាត់ការ និងត្រូវបានមហាអយ្យការអមសាលាសាលាឧទ្ធរណ៍ភ្នំពេញសម្រេចតម្កល់សេចក្តីសម្រេចរបស់អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។ ហើយខ្លួនស្នើសុំដល់តុលាការសម្រេចឱ្យកូនក្តីខ្លួនបានរួចទោស។ ក្នុងករណីនេះតុលាការយល់ឃើញថា: ការស្នើសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនេះពុំមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់នោះទេ គប្បីតុលាការពុំទទួលយកមកពិចារណា ដោយហេតុថាការពិចារណាអំពីអង្គហេតុរបស់អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ក៏ដូចជាមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ គឺពិចារណាទៅលើភស្តុតាងជាក់ស្តែងដែលមាននៅក្នុងសំណុំរឿង ហើយការសម្រេចតម្កល់រឿងទុកឥតចាត់ការនោះទៀតសោតនឹងមិននាំឱ្យមានអាជ្ញាអស់ជំនុំនោះទេ។ ដោយឡែកតុលាការសម្រេចលើអង្គហេតុនេះ គឺផ្អែកលើដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរដែលបានប្តឹងមកតុលាការ ព្រមទាំងភស្តុតាងផ្សេងៗដែលមានក្នុងសំណុំរឿងតែប៉ុណ្ណោះ។

៩-យល់ឃើញថា: ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនហេង និងឈ្មោះ [redacted] ប៊ុនសុវណ្ណ បានប្តឹងទាមទារសំណងការខូចខាតចំនួន ២,០០០,០០០ (ពីរលាន) ដុល្លារអាម៉េរិក និងសំណងជំងឺចិត្តចំនួន ២៥០,០០០ (ពីរសែនប្រាំម៉ឺន) ដុល្លារអាម៉េរិក ពីជនជាប់ចោទឈ្មោះ ឆាយ សៀងលី ប៉ុន្តែផ្អែកតាមពាក្យសុំជូនពិនិត្យភស្តុតាងចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ របស់លោក[redacted] ជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ភស្តុតាងជាឯកសារជូនតុលាការពិនិត្យដើម្បីបញ្ជាក់អំពីការទាមទារសំណងការខូចខាតរបស់ខ្លួននៅក្នុងសំណុំរឿងខាងលើនេះ ឃើញថា: ការបាត់បង់ និងការខូចខាតសរុប គឺមានទំហំទឹកប្រាក់ចំនួន ១,៦៧៦,៤២០ (មួយលានហុកប្រាំពីរម៉ឺនប្រាំមួយពាន់បួនរយម្ភៃ) ដុល្លារអាម៉េរិក។ ក្នុងករណីនេះតុលាការយល់ឃើញថា: ភស្តុតាងរបស់លោក [redacted]សាវុឌ្ឍី បានដាក់ជូនតុលាការពិនិត្យនេះ គឺមានចំនួនច្បាស់លាស់ហើយ ប៉ុន្តែផ្អែកតាមពាក្យបណ្តឹងចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ គឺដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់អំពីចំណែកនៃការទិញដីមួយកន្លែងដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០២០១-១៣៧៥ នោះ គឺមានចំណែករបស់ដើមបណ្តឹងឈ្មោះ [redacted] ប៊ុនហេង ចំនួន ២៥% ដែលស្មើនឹងទឹកប្រាក់សរុបចំនួន ៤១៩,១០៥ (សែសិបមួយម៉ឺនប្រាំបួនពាន់មួយរយប្រាំ) ដុល្លារអាម៉េរិក និងដើមបណ្តឹងឈ្មោះ[redacted]ប៊ុនសុវណ្ណ ចំនួន ១០% ដែលស្មើនឹងទឹកប្រាក់សរុបចំនួន ១៦៧,៦៤២ (ដប់ប្រាំមួយម៉ឺនប្រាំពីរពាន់ប្រាំមួយរយសែសិបពីរ) ដុល្លារអាម៉េរិក តែប៉ុណ្ណោះ។ ហេតុនេះគប្បីតុលាការបង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សៀងលី សងសំណងការខូចខាតឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ប៊ុនហេង ចំនួន ៤១៩,១០៥ (សែសិបមួយម៉ឺនប្រាំបួនពាន់មួយរយប្រាំ) ដុល្លារអាម៉េរិក និងឈ្មោះ [redacted]ប៊ុនសុវណ្ណ ចំនួន ១៦៧,៦៤២ (ដប់ប្រាំមួយម៉ឺនប្រាំពីរពាន់ប្រាំមួយរយសែសិបពីរ) ដុល្លារអាម៉េរិក។ ចំណែកឯលោកមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានទាមទារសំណងជំងឺចិត្តចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាម៉េរិក ពីជនជាប់ចោទ ប៉ុន្តែដើមបណ្តឹងពុំបានដាក់ភស្តុតាងជូនតុលាការអំពីទំហំនៃការចំណាយផ្សេងៗរបស់ខ្លួនជូនតុលាការពិនិត្យឱ្យបានច្បាស់លាស់នោះទេ។ ហេតុនេះគប្បីតុលាការ ពិចារណាអំពីសំណងនេះ និងគប្បីសម្រេចឱ្យសងជាប្រាក់រៀលវិញ។



Scanned with CamScanner

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សៀងលី ភេទស្រី អាយុ៣៦ឆ្នាំ (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០១ (មួយ) ឆ្នាំ ពីបទ: ផ្តល់សេចក្តីប្រកាសដោយភូតកុហក, បំភាន់មន្ត្រីសុរិយោដីក្នុងការចុះបញ្ជីដី និងបទ: លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅចំណុចភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦៣៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៥២ និងមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សៀងលី សងប្រាក់ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនហេង ចំនួន ៤១៩,១០៥ (សែសិបមួយម៉ឺនប្រាំបួនពាន់មួយរយប្រាំ) ដុល្លារអាម៉េរិក និងសំណងជំងឺចិត្តចំនួន ១០,០០០,០០០ (ដប់លាន) រៀល ការទាមទារលើសពីនេះត្រូវច្រានចោល។

៣-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនសុវណ្ណ ចំនួន ១៦៧,៦៤២ (ដប់ប្រាំមួយម៉ឺនប្រាំពីរពាន់ប្រាំមួយរយសែសិបពីរ) ដុល្លារអាម៉េរិក និងសំណងជំងឺចិត្តចំនួន ១០,០០០,០០០ (ដប់លាន) រៀល ការទាមទារលើសពីនេះត្រូវច្រានចោល។

-សាលក្រមនេះបានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ នៅសាលាដំបូងខេត្តតាកែវ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនហេង និងឈ្មោះ [redacted] ប៊ុនសុវណ្ណ និងជនជាប់ចោទឈ្មោះ [redacted] សៀងលី។

-ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍នៅក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា: [redacted]

---

(បានថតចម្លងត្រឹមត្រូវតាមលិខិតដើម)
ថ្ងៃអង្គារ ១៤រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
តាកែវ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២
**ក្រឡាបញ្ជីសវនាការ**
[redacted]

បានឃើញ
តាកែវ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២
**ចៅក្រមជំនុំជម្រះ**
[redacted]



Scanned with CamScanner